# ទស្សនវិទូ ក្លែអង់

## Cléanthe

ក្លែអង់,កូនប្រុសរបស់ Phanias, មានស្រុកកំណើតនៅ Asso ហើយ រស់នៅធ្វើជាអត្តពលករកីឡាប្រដាល់ក្បាច់បុរាណក្រិក។លោកបានមករស់នៅទីក្រុងអាតែនមានលុយតែបួន Drachmes ក្នុងកាបូប ហើយបានទៅរកជួបទស្សនវិទូ Zénon។ Cléanthe ព្យាយាមរៀនសូត្រទស្សនវិជ្ជាណាស់ហើយមិនដែលឃ្លៀងឃ្លាតចេញពីទ្រឹស្ដីរបស់លោកគ្រូហែ្បនណុងឡើយ។លោកក្លែអង់ល្បីឈ្មោះក៏ដោយសារលោកស្រលាញ់ការងារដែរ។រស់នៅក្នុងសភាពក្រីក្រ,លោកធ្វើការស៊ីឈ្នួលដងទឹកពេលយប់អោយម្ចាស់ចំការបន្លែម្នាក់,ដើម្បីពេលថ្ងៃលោកអាចរៀនទស្សនវិជ្ជា។ដោយហេតុដូច្នេះហើយបានជាគេនាំគ្នាហៅលោកថា អ្នកដងទឹក។Antigone ថ្ងៃមួយពេលមកស្ដាប់លោកនិយាយ បានសួរទៅកាន់លោកថា៖ ហេតុម្ដេចបានជាលោកដងទឹក?។លោកក៏ឆ្លើយថា ៖«ខ្ញុំមិនមែនធ្វើតែកិច្ចការនេះប៉ុណ្ណោះទេ។ចុះខ្ញុំអត់ជីកដីទេអី?ហើយខ្ញុំមិនស្រោចដំណាំទេអី?ហើយខ្ញុំមានធ្វើអីខ្លះទៀតទេដោយសេចក្ដីស្រលាញ់ចំពោះទស្សនវិជ្ជា?»មានយុវជនម្នាក់ជាអ្នកនិយាយសើចលេងបានបន្ទោសជរាភាពរបស់លោក, ជាហេតុនាំអោយលោកក្លែអង់តបសំដីទៅថា៖ ខ្ញុំក៏ចង់ចាកចេញពីលោកនេះទៅដែរ,ប៉ុន្តែដល់ឃើញថាខ្ញុំនៅមានសុខភាពល្អ ហើយអាចអានហើយសរសេរបានទើបខ្ញុំដូរគំនិតវិញ ,អញ្ចឹងខ្ញុំក៏រស់នៅបន្តទៀត។ខាងក្រោមនេះបង្ហាញអោយដឹងថាលោកស្លាប់របៀបម៉េច៖លោកកើតមានសាច់ដុះនៅអញ្ចាញធ្មេញហើយតាមបញ្ជាពីវេជ្ជបណ្ឌិត,លោកត្រូវតែតមអាហាររយៈពេលពីរថ្ងៃ។លោកព្យាយាមរហូតបានជាសះស្បើយ ហើយវេជ្ជបណ្ឌិតក៏អនុញ្ញាតអោយលោកបរិភោគអារហារជាធម្មតាឡើងវិញបាន។ប៉ុន្តែលោកមិនព្រមធ្វើតាមវេជ្ជបណ្ឌិតក៏នៅតែមិនបរិភោគអាហារដោយអះអាងថាលោកបានធ្វើដំណើរផ្លូវឆ្ងាយល្មមគួរសមហើយ។ចឹងហើយលោកក៏ទទួលអនិច្ចកម្មទៅ នៅជន្មាយុ៨០ឆ្នាំ ក្រោយពីបានធ្វើជាសាវ័ករបស់ Zénon អស់រយៈពេល១៩ឆ្នាំមក។